**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ០៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអនុគណៈកម្មាធិការ នៃផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៣/២៦៦ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៣ ស្តីពីការកែសំរួល និងតែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកស/០៩០៣/២៨២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការសំរួល និងតែងតាំងសមាជិកក្រុមប្រឹក្សា និងគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គតំណាងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ-បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- តាមសំណូមពរចាំបាច់នៃការងារ

## សំ រេ ច

**មាត្រា ១.-**

បង្កើតអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សំរាប់ការកសាង និងការអនុវត្តកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**មាត្រា ២.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានសមាសភាពដូចតទៅ:

១. សមាជិកគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ តំណាងអោយប្រទេសកម្ពុជា..........ប្រធាន
២. អគ្គនាយកនៃក្រសួងផែនការ..........អនុប្រធាន
៣. អគ្គនាយក ទទួលបន្ទុកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម..........អនុប្រធាន
៤. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងសាធារណការ និងដឹកជញ្ជូន....សមាជិក
៥. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងបរិស្ថាន..........សមាជិក
៦. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........សមាជិក
៧. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ..........សមាជិក
៨. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល..........សមាជិក
៩. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់..........សមាជិក
១០. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងអភិវឌ្ឍន៍ជនបទ..........សមាជិក
១១. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងទេសចរណ៍..........សមាជិក
១២. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងមហាផ្ទៃ..........សមាជិក
១៣. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន..........សមាជិក
១៤. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ..........សមាជិក

**មាត្រា ៣.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គមានភារកិច្ចដូចតទៅ:

- ពិនិត្យឡើងវិញ និងអនុម័តលើផែនការការងារ របាយការណ៍នៃដំណើរវិវឌ្ឍន៍ និងឯកសារដទៃទៀតដែលទាក់ទងការកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ អោយស្របទៅនឹងកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ទិសដៅ និងនីតិវិធីអភិវឌ្ឍន៍អាងទន្លេមេគង្គរបស់ជាតិ

- សំរបសំរួលជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងដោយឡែកជាមួយអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដើម្បីធានាបានថារាល់សកម្មភាពការងារទាំងឡាយ ស្របគ្នាជាមួយនឹងបណ្ដាសកម្មភាពការងារដែលកំពុងអនុវត្តក្នុងប្រទេសនៅតាមដងទន្លេមេគង្គ

- សំរួលដល់កិច្ចសហការរវាងអន្តរស្ថាប័ន និងការកៀងគរធនធានដែលជាតំរូវការរបស់ជាតិសំរាប់អោយការកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គមានដំណើរការទៅមុខ

- ពិនិត្យតាមដាន និងវាយតំលៃលើការវិវឌ្ឍនៃការកសាង និងការអនុវត្តគំរោងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ រួមមានការធ្វើសេចក្ដីសំរេចចិត្តនានា និងការជំរុញការអនុវត្តអោយបានទាន់ពេលវេលា

- ធ្វើរបាយការណ៍ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អំពីការវិវឌ្ឍនៃការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងដោយឡែកអំពីបញ្ហានានាដែលពាក់ព័ន្ធការអភិវឌ្ឍអាងទន្លេមេគង្គរបស់ជាតិ ដែលតំរូវអោយមានការពិនិត្យ និងពិចារណាបន្ថែម

- លើកសំណើជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា លើការចាត់តាំង ការផ្លាស់ប្ដូរសមាសភាពអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងក្រុមការងារផ្សេងៗទៀតរបស់ជាតិសំរាប់ការអនុវត្តកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ

- ពិនិត្យ និងអនុម័តលើលក្ខខណ្ឌការងាររបស់អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គនិងក្រុមការងារផ្សេងៗទៀតរបស់ជាតិ ដើម្បីដាក់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាពិនិត្យ និងសំរេច

- ផ្ដល់ការណែនាំដល់អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងអនុសាសន៍នានាដែលទាក់ទងនឹងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដល់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

- ធ្វើការវាយតំលៃ និងអនុម័តលើសមាហរណកម្មគំរោង ឬកម្មវិធីថ្នាក់ជាតិដែលស្នើឡើងដោយអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដើម្បីដាក់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាពិនិត្យ និងសំរេច ។

**មាត្រា ៤.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គជាសេនាធិការ ស្ថិតនៅក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ត្រូវបង្កើតឡើងដោយសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ត្រូវធ្វើការប្រជុំសាមញ្ញ បី(០៣)ដង យ៉ាងតិចក្នុងមួយឆ្នាំ និងការប្រជុំវិសាមញ្ញតាមតំរូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**មាត្រា ៦.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រធានស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ថ្នាក់ និងសមាជិកអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦. ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

**លឹម គានហោ**
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ